# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0165**

## សម្ភាសន៍ជាមួយឈ្មោះ សឿ សូត្រ ភេទស្រី អាយុ៤៩ឆ្នាំ

## មុខងារខ្មែរក្រហមៈ “នៅកងកុមារ”

## សព្វថ្ងៃរស់នៅភូមិស្រះខាងលិច ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ឡុង ដានី

## ០០:៤៦:១៣

## ២៣ទំព័រ

ដានី : អញ្ជើញជំរាបសួរសុំសួរឈ្មោះមីង មីងឈ្មោះពេញឈ្មោះអី?

សូត្រ : ឈ្មោះ សឿ សូត្រ ។

ដានី : មីងអាយុប៉ុន្មានហើយ?

សូត្រ : អាយុ៤៩ឆ្នាំ ។

ដានី : មីងមានស្រុកកំណើតនៅណាដែរ?

សូត្រ : នៅភូមិស្រះខាងលិច ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

ដានី : ចុះសព្វថ្ងៃរស់នៅភូមិអីដែរ?

សូត្រ : នៅភូមិស្រះខាងលិច ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

ដានី : ចុះប្ដីរបស់អ្នកមីងឈ្មោះអីដែរ?

សូត្រ : ឈ្មោះ អ៊ី ប៊ុន ។

ដានី : សព្វថ្ងៃគាត់អាយុប៉ុន្មានហើយ?

សូត្រ : អាយុ៤៨ ។

ដានី : មីងមានកូនចៅប៉ុន្មាននាក់ដែរ?

សូត្រ : ខ្ញុំមានកូន៤នាក់ ។

ដានី : ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សូត្រ : ស្រី២ ប្រុស២ ។

ដានី : មីងសព្វថ្ងៃប្រកបមុខរបរធ្វើអីដែរ?

សូត្រ : ខ្ញុំរកតែត្រី រកត្រីធ្វើប្រហុក ត្រីប្រហុក ។

ដានី : អត់មានធ្វើអីទៀតទេ?

សូត្រ ៖ អត់មានទេ ធ្វើចំការតិចតួចហ្នឹងឯង ។

ដានី ៖ ឪពុកមីងគាត់ឈ្មោះអីទៅ?

សូត្រ ៖ ឪពុកខ្ញុំគាត់ឈ្មោះ ដន ប៉ុននាមត្រកូលគាត់ខ្ញុំមិនដឹងទេ គាត់ខូចយូរហើយ ។

ដានី ៖ គាត់ខូចយូហើយ?

សូត្រ ៖ ចា៎!ខ្ញុំកំព្រាតាំងពីតូចនោះ ។

ដានី ៖ ចុះម្ដាយ?

សូត្រ ៖ ម៉ែខ្ញុំឈ្មោះ សៀន ។

ដានី ៖ ឈ្មោះ សៀន គាត់នៅរស់ឬក៏ស្លាប់ហើយ?

សូត្រ ៖ ស្លាប់តាំងខ្ញុំនៅតូចៗ ខ្ញុំកំព្រាតាំងពីតូច ។

ដានី ៖ ចុះមីងមានបងប្អូនបង្កើតប៉ុន្មាននាក់?

សូត្រ ៖ បងប្អូន៦នាក់ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សូត្រ ៖ ប្រុស៥ ស្រីតែមួយហ្នឹងឯង ។

ដានី ៖ ចុះមីងកូនទីប៉ុន្មាន?

សូត្រ ៖ ខ្ញុំកូនទី៣ ។

ដានី ៖ ចុះកាលពីក្មេងៗបានរៀនអីដែរឬអត់?

សូត្រ ៖ រៀនតាំងពីសម័យអាពត រៀនបានតិច រៀនមិនទាន់ចេះបាន“ក ខ”ផងគេកយកទៅ កន្លែងលើកទំនប់ គេជ្រើសរើសយកតែអ្នកធំទៅ អកមាឌធំៗ អាយុវាអត់គិតទេ វាគិតតែអ្នកណាធំយក ។

ដានី ៖ កាលហ្នឹងមីងរៀនកាលជំនាន់ប៉ុល ពតហ្នឹង?

សូត្រ ៖ រៀនកាលប៉ុល ពត សម័យលន់ ណុលខ្ញុំនៅតូច ។

ដានី ៖ អញ្ចឹងមីងពេលដែលប៉ុន ពត ចូលឆ្នាំ៧៥ កាលហ្នឹងមីងនៅណា?

សូត្រ ៖ ខ្ញុំនៅនេះហ្នឹង ។

ដានី ៖ នៅជាមួយពីណាពេលឆ្នាំ៧៥?

សូត្រ ៖ ឆ្នាំ៧៥នៅជុំជាមួយម៉ែឪ ប៉ុនគេយកទៅដាក់នៅមណ្ឌលកុមារ កាប់ទន្ទ្រានខែត្រ ដល់កាប់ៗទៅ ជញ្ជូនទៅលើកទំនប់ គេហៅប្រជុំ គេឲ្យរៀបជាជួរអញ្ចឹងទៅ ក៏វាដើររើសយកអាណាធំៗដកយកៗ ។

ដានី ៖ ជញ្ជូនទៅកាប់ទន្សាន់ខែត្រ?

សូត្រ ៖ ចាំ!

ដានី ៖ កាប់ទន្សាន់ខែត្រនៅណា?

សូត្រ ៖ នៅតាមភូមិនេះឯង ដល់ពេលកាប់បានរយៈពេលមួយឆ្នាំៗ គេឲ្យទៅកាប់នៅ ប៉ុយត្រាវ ចេះតែបញ្ជូនពីណាពីណីចេះតែនាំទៅ ។

ដានី ៖ បញ្ជូនទៅកាប់នៅណាទៀត?

សូត្រ ៖ ទៅកាប់នៅដីបូកស្វាយ ។

ដានី ៖ ដីបូកស្វាយនៅណា?

សូត្រ ៖ ដីបូកស្វាយហួសប៉ោយតាប៉ែនបន្តិច ។

ដានី ៖ ខ្ញុំស្គាល់ប៉ោយតាប៉ែន ប៉ោយតាព្រីង ។ ហើយទៅកាប់ហ្នឹងរយៈពេលប៉ុន្មានទៅ?

សូត្រ ៖ រយៈពេលមួយឆ្នាំៗ ។

ដានី ៖ អញ្ចឹងកាលហ្នឹង កាលហ្នឹងពេលដែលយើងទៅកាប់ទន្សាន់ខែត្រអី យើងនៅជាមួយឪពុកម្តាយធម្មតាទេ?

សូត្រ ៖ យកទៅដល់គេដាក់មកកងអញ្ចឹងទៅ ឲ្យដាំបាយហូបតែគ្នាយើងទៅ ចុងភៅគេមានដល់ទៅកាប់ ។

ដានី ៖ កាលហ្នឹងអាយុប៉ុន្មាន កាលទៅកាប់ទន្សាន់ខែត្រ?

សូត្រ ៖ អាយុ១៥ ។

ដានី ៖ នៅក្នុងហ្នឹងគេហៅកងអីគេ កងកុមារឬកងចល័ត?

សូត្រ ៖ គេហៅកងកុមារហ្នឹង ដល់ពេលគាត់នៅកងកុមារទៅ គេជ្រើសរើសយកអ្នកណាដែលមាឌធំៗខ្ពស់ ខ្ញុំហ្នឹងវាត្រូវប៉ាន់ ។

ដានី ៖ ជ្រើសរើស?

សូត្រ ៖ ជ្រើសរើសយកតែមាឌធំៗ អាយុប៉ុន្មានក៏មិនគិតដែរឲ្យតែមាឌធំ ។

ដានី ៖ ទោះអាយុតិចក៏ដោយ?

សូត្រ ៖ ចាំ!

ដានី ៖ អាយុតិចក៏ដោយគេយកទៅណា?

សូត្រ ៖ យកទៅលើកទំនប់នោះឯង ដេកព្រៃបានមួយយប់ យើងរត់គេចាប់បានទៀត ចាប់ចងមួយយប់មួយថ្ងៃ ។

ដានី ៖ ពេលដែលគេជ្រើសរើសទៅលើកទំនប់ហ្នឹង មីងលួចរត់អីបានគេយកទៅចាប់ចង?

សូត្រ ៖ រត់!លួចរត់ ។

ដានី ៖ គេយកយើងទៅមិនទាន់បានទៅដល់កន្លែងផងលួចរត់?

សូត្រ ៖ ទៅដល់កន្លែងនៅហ្នឹង ទៅដល់លួចរត់ គេរកឃើញគេចាប់ចងៗគេរកយកទៅវៃចោល ដល់ពេលនេះពួកប្រធានៗគេដោះស្រាយ ។

ដានី ៖ អ្នកណាគេអ្នកចាប់បាន ចាប់បានហើយចាប់ចង?

សូត្រ ៖ អត់ស្គាល់ទេ សុទ្ធតែពួកគេទាំងអស់ ចាំមិនបានទេ សុទ្ធតែពួកគេទាំងអស ។

ដានី ៖ គេចាប់ចងគេចងយ៉ាងម៉េច?

សូត្រ ៖ ចងដូចស្លាបសេក សុទ្ធតែធាក់រឹត ធាក់ខ្នងយើងរឹត ។

ដានី ៖ គេធាក់ខ្នងទៀត?

សូត្រ ៖ ចា៎!រឹតចងយើងរឹក ។

ដានី ៖ គេធាក់ច្រើនទេ?

សូត្រ ៖ អ៊ូ!ច្រើនណាស់ វ៉ៃ ។

ដានី ៖ យកអីវ៉ៃ?

សូត្រ ៖ ដំបង ដល់គេដោះស្រាយបានទៅ បានទៅធ្វើការវិញ ។

ដានី ៖ កាលហ្នឹងមីងរត់ពីកន្លែងណាម៉ោកន្លែងណា?

សូត្រ ៖ រត់កន្លែង ពួនកន្លែងនោះឯង ពួនក្នុងដុបទៅគេរកមិនឃើញ វាខឹងវា ។

ដានី ៖ អត់ស្គាល់អ្នកចាប់អ្នកវ៉ៃ?

សូត្រ ៖ មិនស្គាល់ទេ សុទ្ធតែពួកនិរតី ។

ដានី ៖ ឆ្នាំណាដែលគេចាប់?

សូត្រ ៖ ខ្ញុំអត់ចាំទេ មិនដែលបានគិតឆ្នាំគិតអីទេ គិតមិនចេញ ។

ដានី ៖ កាលហ្នឹងមីងរត់ម្នាក់ឯងឬមានអកផ្សេងរត់ដែរ?

សូត្រ ៖ គ្នាប្រហែល២០នាក់ ។

ដានី ៖ ២០នាក់រត់ទាំងអស់ ចាប់បានទាំងអស់វ៉ៃទាំងអស់?

សូត្រ ៖ ចា៎!ដល់គេវ៉ៃខ្លាំងៗតែខ្ញុំទេ ព្រោះគេថាខ្ញុំអ្នកដឹកនាំគេរត់ ។

ដានី ៖ ចុះកាលរត់ហ្នឹងបានរយៈពេលប៉ុន្មានបានគេដឹង?

សូត្រ ៖ ម៉ាយប់ម៉ាថ្ងៃអត់បាយ ។

ដានី ៈ អញ្ចឹងដល់ពេលគេចាប់ហ្នឹង គេធ្វើទារុណកម្មមីង គេវៃគេចងដល់រយៈពេលប៉ុន្មានទៅបានទៅដោះឡែងវិញ?

សូត្រ ៈ គេវៃមួយយប់ ប៉ុនគេវៃហ្នឹងមិនវៃឲ្យងាប់ទេ គេវៃឲ្យរស់ ប៉ុនដៃនេះវាហើមប៉ុនៗនេះ ហើមដល់វាស្រាយលែងទៅបានស្រកមកវិញ ។

ដានី ៈ វៃនៅភូមិណា?

សូត្រ ៈ នៅភូមិហ្នឹងឯង នៅកន្លែងធ្វើការហ្នឹង ។

ដានី ៈ កន្លែងដំបូងស្នាយហ្នឹង?

សូត្រ ៈ ចា៎!ហ្នឹងហើយ ដល់វាស្រាយលែងយើងទៅវាឲ្យបាយស៊ីមួយពេល ឲ្យស៊ីបាយស៊ីម្ហូប ហើយវាឲ្យទៅ វាថាយកយើងទៅទុកដេកស៊ីឲ្យមានកម្លាំង មិនមែនយកទៅលើកទំនប់ ទេ អញ្ចឹងយើងក៏ទៅ គេហៅទៅៗមានអី ឃើញបង្គីប៉ុនៗនេះមានអី ធ្លាក់ថ្លើមគ្គុក ។

ដានី ៈ ទៅលើកទំនប់នៅណា?

សូត្រ ៈ នៅត្រពាំងថ្មហ្នឹង ។

ដានី ៈ នៅត្រពាំងថ្ម?

សូត្រ ៈ ចា៎!ទៅគ្នាច្រើនណាស់ គ្នាម៉ាខេត្តម៉ាភូមិនោះ ។

ដានី ៈ កាលមីងទៅលើកទំនប់នៅត្រពាំងថ្មហ្នឹងមីងនៅលើកណា?

សូត្រ ៈ ចាំបានបន្តិចថា កាលចូលទៅដល់ដំបូងមិនដឹងណាដើងត្បូងទេ មិនមានស្រលះដូចយើងឥឡូវទេ ទៅគេវាស់យកៗគេដាក់ឲ្យយើងលើក ហើយយើងគិតតែពីលើកទៅ ។

ដានី ៈ បាទ!កាលហ្នឹងមីងនៅកងជាមួយពីណាគេ?

សូត្រ ៈ ខ្ញុំនៅកង៣០ ប៉ុន្តែប្រធានហ្នឹង រឹងសួរប្រធានថា មិនហ៊ានមើលមុខគេទេ មិនស្គាល់ទេ ដឹងតែចាំបានថាកង៣០ ដាក់កងទី១ ទី២ ទី៣ ទី៤ ទី៥រហូតដល់ទី៣០ ។

ដានី ៈ នៅកង៣០?

សូត្រ ៈ នៅកងទី៣០

ដានី ៈ ចុះមីងអត់ស្គាល់គេទេ?

សូត្រ ៈ មិនស្គាល់ទេ ស្ទុតែនិរតីទាំងពីរ សូម្បីតែកន្លែងដាំបាយវាកន្លែងអីវា វាមិនឲ្យដើរកាត់ទេ ។

ដានី ៈ ចុះនៅកន្លែងកង៣០ ម៉ាកងមានគ្នាប៉ុន្មាននាក់?

សូត្រ ៖ មានម៉ាកឥគ្នា៣០នាក់ គ្នា៣០នាក់ហ្នឹងមានប្រធាន៣នាក់ ប្រធានកង ប្រធានអនុ សមាជិកប្រធានស្ត្រីទេខ្ញុំមិនចាំទេ ។

ដានី ៖ ប្រធាន៣នាក់ តែមីងអត់បានធ្វើប្រធានអីគេទេ?

សូត្រ ៖ ទេ!មិនបានធ្វើទេ ។

ដានី ៖ ចុះប្រធានគេធ្វើការអីប្រអត់?

សូត្រ ៖ ប្រធានធ្វើ ប៉ុនគេគ្រាន់តែដើរវាស់ឲ្យយើងប៉ុណ្ណោះឯង ។

ដានី ៖ គេគ្រាន់តែវាស់ឲ្យយើងទេ គេអត់ធ្វើការខ្លួនឯងទេ?

សូត្រ ៖ ទេ!អត់ទេ គេវាស់តែ ខបមាថាគេវាស់ឲ្យយើង៣ម៉ែត្រគឺបអញ្ចឹង គេវាស់តែទទឹង បណ្ដោយចាក់ចេះ តែបានតែជំរៅមួយម៉ែត្រ ទទឹង៣ម៉ែត្រ បណ្ដោយ៣ម៉ែត្រយើង បានហូបបាយ បើថាយើងមិនបានទេបាយយើងមិនបានហូបទេ ហើយដល់យើងលើក រួចអា៣ម៉ែត្រគឺបហ្នឹងរួច ស្អែកឡើងគំឡើង៣ម៉ែត្រគឺបកន្លះ ដល់យើងលើក៣ម៉ែត្រ គឺបកន្លះរួច គេគំឡើង៤ម៉ែត្រគឺប វាគំឡើងរាល់ថ្ងៃ ឡើងដល់៣-៤ម៉ែត្រគឺបលើក មិនរួចទេម៉ោង១០-១១នោះបានរួច ចុះឡើងៗទាល់តែស្គម ។

ដានី ៖ ឡើងរហូតអញ្ចឹង ឡើងទាល់តែលើកលែងរួច?

សូត្រ ៖ ចា៎!ហ្នឹងហើយ ។

ដានី ៖ ដល់ពេលយើងលើកអត់រួចអញ្ចឹងធ្វើយ៉ាងម៉េចទៅ?

សូត្រ ៖ លើកទាល់តែរួច យើងលើកមិនរួចព្រឹកឡើងយើងក្រោកធ្វើបង្ហើយឲ្យគេ បង្ហើយអា ហ្នឹងរួចគេវាស់ឲ្យទៀត វាស់ឲ្យទៀតខបមាថាយើងលើកមិនរួចទៀត យើងទុកព្រឹក ក្រោយបង្ហើយទៀត តែអញ្ចឹងរហូត ដល់យើងមានបងមានប្អូនទៅលេងដូចថា គ្រាន់ តែសុំទៅលេង បងប្អូនម៉ោលេងក៏អត់បានដែរ តែទៅលួចទៅ បើបងប្អូនទៅជួបឃើញ វេទនាគេជួយម៉ារីបទៅរួច ក៏ទៅបាត់ទៅ អាល័យទៅនេះទៅនោះ មើលជើងខ្ញុំ មើល ។

ដានី ៖ អាហ្នឹងតាំងពីជំនាន់ ប៉ុល ពតម៉្លេះ?

សូត្រ ៖ ចា៎!

ដានី ៖ អាហ្នឹងកើតអីជើងហ្នឹង?

សូត្រ ៖ អាហ្នឹងខ្ញុំនាំឡើង វែកដីឡើង ។

ដានី ៖ អ្ហូ!វែកឡើងខ្ពស់ទេ?

សូត្រ ៖ ខ្ពស់ណាស់ កម្ពស់៣ម៉ែត្រកន្លះ ។

ដានី ៖ កម្ពស់៣ម៉ែត្រកន្លះ?

សូត្រ ៖ ចា៎!

ដានី ៖ ចុះទទឹង បណ្តោយប៉ុន្មាន?

សូត្រ ៖ ទទឹងចាំមិនបានទេៗ មិនដែលបានដើរទេ យើងមិនហ៊ានដើរដូចថាដើរចេះឆ្លងកាត់ដើរមើលលិចកើតក៏អត់បានៗ ។

ដានី ៖ នៅតែលើកបាន?

សូត្រ ៖ នៅតែកន្លែងទំនប់លើកដី មកកន្លែងចែកបាយចែកបបរ ។

ដានី ៖ ចុះពេលលើកហ្នឹងយើងធ្វើទាំងកណ្តាលថ្ងៃ ឬគេធ្វើវេនមួយ?

សូត្រ ៖ គ្មានវេនលើកទេ សូម្បីតែវេននៅក៏អត់មានដែរ ។

ដានី ៖ អ្ហូ! ម៉េចអញ្ចឹង?

សូត្រ ៖ បាំងតែស្នឹងឈើចេះ ភ្លៀងម៉ោដេកហាលភ្លៀង ដល់ពេលវាបាំងឲ្យមើលទៅវាវេទនាខ្លាំងភ្លៀងខ្លាំងក៏យកធាងត្នោតអាវាកាប់ទាំងធាងៗ ៗវាយកគ្របទៅ គ្មានអីមិនជិតយប់ឡើងអាស៊ិ(អស់កម្លាំង) ខ្លាំងដេកទៅ ភ្លៀងម៉ោទទឹកហូរដោកអស់ពេញខ្លួន ។

ដានី ៖ ហើយដេកលក់ដែរ?

សូត្រ ៖ លក់ ចុះបើស៊ិខ្លាំងមិនលក់ ។

ដានី ៖ ស៊ិម៉េច?

សូត្រ ៖ អស់កម្លាំងខ្លាំង គ្រាន់តែអាវគ្រាន់តែឡើងអំបិលសឹងតែកន្លះ ប៉ុននេះ ។

ដានី ៖ អត់បានបោកខោអាវទេ?

សូត្រ ៖ អត់មានទឹកទេ ទឹកចែកគ្នាម៉ាផ្តិល៣នាក់ ។

ដានី ៖ ចុះចាប់ផ្តើមធ្វើការពីម៉ោងប៉ុន្មាន?

សូត្រ ៖ ចាប់ពីម៉ោង៥ព្រឹក ម៉ោង៨វេរដួង ម៉ោង៥ដឹងតែចូល បើអ្នកណាចេញមិនទាន់គេដងរែកដាក់ក្ងសៗ ។

ដានី ៖ ពីណាដាក់?

សូត្រ ៖ ប្រធានវាហ្នឹងឯង ប្រធានធំជាងគេហ្នឹង ។

ដានី ៖ ប្រធាន៣០នាក់ឬប្រធានធំជាងហ្នឹងទៀត?

សូត្រ ៖ ធំជាងហ្នឹងទៀត ។

ដានី ៖ ប្រធានអីគេហ្នឹង?

សូត្រ ៖ គេហៅថាសហករណ៍ អ៊ុស៎!ប្រធានកង បើគ្នា៣០នាក់ហ្នឹងប្រធានក្រុម អាប្រធានធំនោះគេហៅប្រធានកង ។

ដានី ៖ ប្រធានធំជាងគេឈ្មោះអី?

សូត្រ ៖ អត់ស្គាល់ទេ វាសឹងតែដើរវាមិនដែលចេញមុខឲ្យយើងឃើញទេ វាហ៊ុំជិតចេះមួកកាតិបវាដាក់ឡើងផ្ចិបៗមិនឲ្យឃើញទេ ស្រីក៏ដូចប្រុសៗក៏ដូចស្រី ។

ដានី ៖ អញ្ចឹងចាប់ធ្វើការពីម៉ោប៉ុន្មាន ម៉ោង៥?

សូត្រ ៖ ពីម៉ោង៥ដល់ម៉ោង៨ល្ងាច ស៊ូមិនបានស្រេចតែម៉ារួច ។

ដានី ៖ ចុះពេលហូបបាយថ្ងៃម៉ោងប៉ុន្មាន ម៉ោង៥?

សូត្រ ៖ អត់មានបាយថ្ងៃទេ ។

ដានី ៖ អត់មានបាយថ្ងៃទេ?

សូត្រ ៖ អត់ទេ!

ដានី ៖ ចុះយើងមានកម្លាំងពីណាមកធ្វើការអញ្ចឹង?

សូត្រ ៖ គ្មានចេះតែទៅៗ បើឃើញដងវែកវាដាក់ដូសៗ មានអីចេះតែហូប ។

ដានី ៖ ចុះពេលព្រឹកមានអីបុកអត់?

សូត្រ ៖ អត់មាន!ម៉ោង១២ ។

ដានី ៖ ម៉ោង១២បានបាយហូប?

សូត្រ ៖ ចា៎!បានហូបបាយម៉ាចាន ។

ដានី ៖ ចានប៉ុណ្ណា?

សូត្រ ៖ កូនចានចំហុយប្រហុក ។

ដានី ៖ ម៉ាកូនចានចង្កេះហ្នឹង?

សូត្រ ៖ ហ្នឹងហើយ ។

ដានី ៖ ហូបឆ្អែតដែរម៉ាកូនចានចង្កេះ?

សូត្រ ៖ ម៉េចឆ្អែត ។

ដានី ៖ អត់ឆ្អែតទេ?

សូត្រ ៖ អត់ឆ្អែតទេ ។

ដានី ៖ អត់ឆ្អែតយើងហូបអីថែមទៀត?

សូត្រ ៖ ស្លឹកឈើ ។

ដានី ៖ ស្លឹកឈើណា បើនៅកណ្ដាលវាលហ្នឹង?

សូត្រ ៖ មានៗព្រៃ ហើយស្លឹកអំពិល ហើយស្លឹកប្រាប់អូនឯងៗមិនស្គាល់ទេដឹង ។

ដានី ៖ ស្លឹកអីគេ?

សូត្រ ៖ ស្លឹកឈើឲ្យតែរបស់យើងស៊ីកើត ហើយដើមកន្ទុំយើង កន្ទុំប្រៃយើងយកទៅស្ងោរ ទៅណា៎ ស្លឹកប្បាស ។

ដានី ៖ ស្ងោរបានដែរ?

សូត្រ ៖ ស្ងោរបានយ៉ាងច្រើនសុំបានតែអំបិលគេឲ្យតែប៉ុនហ្នឹង យើងដាក់តែប្រហុកទៅ ឃ្លាន ខ្លាំងដល់ថ្នាក់ស៊ីកណ្ដុរឆៅ រ៉ៃចោលផាប់អស់ កណ្ដុរឆៅក៏ស៊ីដែរឃ្លានខ្លាំងពេក ។

ដានី ៖ កណ្ដុរម៉ោពីណាមក?

សូត្រ ៖ កណ្ដុរដែលយើងជីកដីទៅវាចេញមក ប៉ុន្តែខ្ញុំមិនបានស៊ីទេ ពួកអ្នកថ្មីស៊ីឆៅទៅវា ឃើញវាយកទៅរ៉ៃចោលទៅ ។

ដានី ៖ កណ្ដុររស់ហ្នឹង?

សូត្រ ៖ កណ្ដុរយើងបកទៅ យើងពន្រាត់វាទៅយើងស៊ីឆៅ ឈាមរលាក់ៗឃ្លានខ្លាំងទៅ ។

ដានី ៖ រួចទៅគេរ៉ៃចោលទៀត?

សូត្រ ៖ រ៉ៃចោល ។

ដានី ៖ ហេតុអីបានគេរ៉ៃចោល?

សូត្រ ៖ គេថាយើស៊ីមិនសំណុំ ។

ដានី ៖ ចុះគេមានដែរឲ្យយើងហូបសាច់គោ សាច់ជ្រូកទេ?

សូត្រ ៖ ទេ!មិនដែលស្គាល់ជាតិទេ ស្គាល់តែថ្ងៃដែលយើងចេញមកធ្វើការឲ្យវា ថ្ងៃលើកពី ដំបូងកាប់ជ្រូក២ឲ្យស៊ី ស៊ីរួចវាបញ្ជូនដាក់ឡានវិញ ។

ដានី ៖ ហើយទៅដល់នោះដូចយើងហូបកណ្ដុរអីហ្នឹងគេថាយើងហូបមិនសំណុំ?

សូត្រ ៖ ហ្នឹងឯង គេយើងវាមើលឆាយគេ គេមិនដែលមានអីឲ្យស៊ីទៅស៊ីអញ្ចេះៗអត់អីហូប បើខ្ញុំបានស៊ីៗខ្យងឆៅ ។

ដានី ៖ ខ្យងឆៅអត់អីទេ?

សូត្រ ៖ លួចស៊ីកុំឲ្យវាឃើញ បើវាស៊ីកណ្ដុរស៊ីទៅ វាប្រឡាក់មាត់ពួកអ្នកថ្មីស៊ីគេរ៉ៃចោល ។

ដានី ៖ គេរ៉ៃចោល?

សូត្រ ៖ រ៉ៃកណ្ដាលថ្ងៃហ្នឹងឯង អត់មាន ។

ដានី ៖ វ៉ៃនៅណា?

សូត្រ ៖ វ៉ៃដាក់ក្នុងទំនប់ហ្នឹង ។

ដានី ៖ វ៉ៃដាក់ក្នុងទំនប់ហ្នឹង ហើយឲ្យយើងមើលឃើញដែរ?

សូត្រ ៖ ឃើញ ។

ដានី ៖ មីងមើលឃើញ?

សូត្រ ៖ គេឲ្យយើងមើលឃើញខ្លាចទៅ បារបុ៉ននេះក៏លើករួចដែលព្រោះដាប់លើកដីឲ្យតែរួច សួរប្រធានភូមិទៅក្បាលជន្លង់ខ្ញុំបុ៉ននេះ ដើរមិនរួចណា៎បានប្រធានភូមិនេះជួយយកមក បានម៉ោ ។

ដានី ៖ ជួយយកពីណាម៉ោ?

សូត្រ ៖ យក ខ្ញុំលួចវាវម៉ោកន្លែងគាត់ កាលខ្ញុំវាវម៉ោមកកន្លែងគាត់ ប្រហែល៣គីឡូ ដើរអត់រួចទេ ប្រធានភូមិគេហៅទៅធ្វើអីទេកាលហ្នឹង ។

ដានី ៖ ពូប្រធានភូមិឈ្មោះតាអី?

សូត្រ ៖ ឈ្មោះតាមឿន ក្នុងម៉ាឃុំព្រះនេត្រព្រះនេះនៅតែខ្ញុំមួយម្នាក់ឯងនៅជាមួយពួកនិរតី ហើយក្រៅពីហ្នឹងសុទ្ធតែស្រុកគេទាំងអស់ ។

ដានី ៖ អញ្ចឹងកាលហ្នឹងយើងធ្វើការ យើងបានហូបបាយតែមួយចានចង្កេះអញ្ចឹង?

សូត្រ ៖ ចានចង្កេះ បុ៉ន្តែថ្ងៃអត់មានទេ ។

ដានី ៖ ពេលម៉ោង១២មួយសារ?

សូត្រ ៖ ម៉ោង១២ ហើយពេលល្ងាចមួយសារ ។

ដានី ៖ មួយពេលមួយចានចង្កេះ?

សូត្រ ៖ ចានចង្កេះ ។

ដានី ៖ បានសម្លអី?

សូត្រ ៖ ថ្ងៃណាស្លម្ជូរត្រកួន ថ្ងៃណាស្លម្ជូរត្រកួកនោះ អាត្រកួនដូចថាវែង១នេះ ពីនេះទៅរបង យើងកាត់ដាក់ទៅ ត្រកួនយើងត្រកួនស្រែយើងហ្នឹង អាចាស់១ហ្នឹងកាត់ដាក់ទៅ សាច់ជ្រូកដូចថាប្រវែងនេះម៉ាខ្ទះ គេហាន់ឲ្យស្តើង១ដាក់បណ្តែតទៅ ស្លឲ្យឆ្អិន១ហូបទៅ ហើយបើថាបាយ មុនដំបូងទៅបានបាយមួយចានចង្កេះបាយ ដល់ពេលយូរ១ទៅ បបរ១មុនដំបូងប៊ិក១ដល់យូរទៅរាវ ។

ដានី ៖ យូរ១ទៅរាវ?

សូត្រ ៈ ពាវ ឆាប់អស់មិនតិចទេ ខ្លះឆាប់ដេកៗឆាប់ បើយើងគ្រុនស្ទាបខ្លួនដល់ក្តៅគគីសបាន ថាគ្រុន បើថាឈឺពោះអញ្ចេះ ពេទ្យម៉ោពិនិត្យថា បើខបមាថាអ្នកឈឺល្មមៗ យកល្អ ដូចថាវាអស់កម្លាំងខ្លាំងទៅមិនរួចដងវែកវាវៃ វៃដូចចរ(ចរ = ផ្លែ) អញ្ចឹង ចរសព្វថ្ងៃ មិនវៃដូចពួកខ្ញុំទេ ។

ដានី ៈ វៃម៉េច?

សូត្រ ៈ វៃដងវែកដាក់ពីងៗ ត្រូវក្បាលត្រូវៗទៅ ត្រូវត្រង់ណាត្រូវៗទៅ ។

ដានី ៈ គេវៃពីងៗយើងអត់ហ៊ានរត់ទេ?

សូត្រ ៈ មិនហ៊ានរត់ទេ រត់យកទៅវៃចោល សុទ្ធចិត្តឲ្យវាវៃឲ្យអស់ចិត្តវាទៅ ហើយវាឈប់ទៅ គេស្តីឲ្យដើរចេញទៅ ។

ដានី ៈ គេស្តីឲ្យថាម៉េចម៉េចទៀត?

សូត្រ ៈ គេថាមិត្តឯង«ទុកក៏មិនចំណេញ ដកចេញក៏មិនខាត» វាយើងទន្រ្ទេនយើងធ្វើការ ទន្រ្ទេន ។

ដានី ៈ ចុះគេអត់មានធ្វើបន្លែមឲ្យយើងហូបទេ?

សូត្រ ៈ អ៊ូ!មិនដែលស្គាល់ជាតិទេៗ បើគេធ្វើអាបុណ្យអីនោះគ្រាន់ បានហូបបាយគ្រាន់ ៧មករាគេនោះ ។

ដានី ៈ បុណ្យ១៧មេសា?

សូត្រ ៈ មិនដឹងទេ មិនចាំទេសួរមិនចាំទេ ។

ដានី ៈ ៧មករាបែក៧៩?

សូត្រ ៈ អេ៎!ស្តីគេបុណ្យគេធ្វើដែលចូលឆ្នាំ ដូចថាបាយគេដូចសំណំ មានម្ហូបសំណំម៉ាពេល ហ្នឹង ។

ដានី ៈ គេឲ្យយើងសម្រាកដែរឬអត់?

សូត្រ ៈ សម្រាកបានមួយថ្ងៃ ថ្ងៃដែលធ្វើបុណ្យនោះសម្រាកបានមួយថ្ងៃ ។

ដានី ៈ សម្រាកយើងធ្វើអីទៅ?

សូត្រ ៈ គ្មានធ្វើអីដេកទៅ ទៅដើរបេះស្លឹកឈើយកមកទុកស៊ីទៅណា៎! ផ្លែឈើផ្លែអី ។

ដានី ៈ អត់ឲ្យម៉ោផ្ទះទេ?

សូត្រ ៈ អត់ឲ្យម៉ោទេ ។

ដានី ៈ យើងសម្រាកអញ្ចឹងក៏អត់ឲ្យម៉ោផ្ទះដែរ?

សូត្រ ៖ សម្រាកក៏នៅកន្លែងហ្នឹង ស៊ីកអំពិលបេះម៉ោដល់ស្ងោរ ស្ងោរដាក់ក្នុងឆ្នាំងឲ្យឆ្អិនបាន ពុះបានអន្លុយស៊ីទៅឲ្យតែពេញពោះ ស៊ីកអំពិលយើងហ្នឹង យកទៅបុកពូតយកអាជាតិជូរចេញ អន្លុយស៊ីទៅ ។

ដានី ៖ ចុះមីងកាលហ្នឹងមីងមានបានចូលប្រជុំគេដែរ?

សូត្រ ៖ ទេមិនដែលបានប្រជុំអី ។

ដានី ៖ គេប្រជុំ គេហៅយើងប្រជុំអីហ្នឹង?

សូត្រ ៖ អ្ហូ!ប្រជុំហៅ ដល់ពេលវាប្រជុំមានផែនការណ៍ហើយប្រជុំ ។

ដានី ៖ ប្រជុំគ្នាច្រើនៗទេ?

សូត្រ ៖ ច្រើនណាស់ រាប់លាន ដូចថាម៉ាខ្សែអញ្ចេះ ដូចម៉ាកង១៣០នាក់ៗទៅណា៎ ។

ដានី ៖ ពីណាគេម៉ោប្រជុំ?

សូត្រ ៖ ពួកប្រធានធំវាហ្នឹង ។

ដានី ៖ ឈ្មោះអីប្រធានធំ?

សូត្រ ៖ មិនស្គាល់ទេ ។

ដានី ៖ មីងដែលស្គាល់ទេ ពេលគេប្រជុំអី?

សូត្រ ៖ ប្រជុំឃើញតែគេប្រជុំពេលយប់ ថ្ងៃអត់ដែលប្រជុំសោះ ។

ដានី ៖ អញ្ចឹងគេអត់ប្រាប់ថាគាត់នេះឈ្មោះនេះ?

សូត្រ ៖ អត់ទេៗ!គេហៅតែសមិត្ត មិត្តប្អូនមិត្តបង មិត្តទី១ទី២គេហៅអញ្ចឹងឯង ឈ្មោះអត់ដែលហៅទេ ។

ដានី ៖ ចុះអត់ដែលហៅឈ្មោះតាវ៉ាល់ទេ?

សូត្រ ៖ អត់ទេ ។

ដានី ៖ ឈ្មោះតាវ៉ាល់ៗអត់ឮទេ?

សូត្រ ៖ អត់ដែលឮហៅទេ បងមនដែលបាន តែឮថាមិនមែនតែមួយថ្ងៃទេអូនអើយ តែហាមាត់និយាយខុសមួយមាត់ងាប់មួយមាត់ យើងមិនដែលហ៊ាននិយាយអី មិនដែលស្តាប់អ្នកណានិយាយពីនោះ អន្លុយ៣នាក់ក៏មិនដែលហ៊ានដែរ ដេកអត់ឲ្យដេកទេគ្នា ៣នាក់ឲ្យដេកតែម្នាក់ៗ គេខ្លាចយើងពិគ្រោះគ្នារឿងអីៗ ។

ដានី ៖ ហើយប្រជុំគេខស្សាហ៍ប្រជុំដែរ?

សូត្រ ៖ ខស្សាហ៍ប្រជុំ ។

ដានី :	ប៉ុន្មានថ្ងៃប្រជុំម្ដង?

សូត្រ :	ថ្ងៃណាទៅម៉ាអាទិត្យទៅ ថ្ងៃណាទៅម៉ាខែ ។

ដានី :	គេប្រជុំគេនិយាយពីអី?

សូត្រ :	និយាយពីរឿងឲ្យយើងធ្វើការងារឲ្យល្អ យើងខិតខំប្រឹងកម្លាំងចិត្ត ប្រឹងម៉េចរួចទេបបរម៉ាចាន បើថាខ្វះទៅក៏ចេះតែប្រឹងបានរស់ខ្វះ ខ្វះងាប់ទៅ ។

ដានី :	មានស្លាប់ច្រើនហ្នឹង?

សូត្រ :	ច្រើនស្លាប់ច្រើន ខ្វះដេកងាប់ ។

ដានី :	ដេកងាប់ទេ គេអត់វៃចោលទេ?

សូត្រ :	វៃចោលក៏ច្រើន ។

ដានី :	វៃចោលច្រើនតែពួកម៉ោពីណា ពួកប្រជាជនថ្មី?

សូត្រ :	ថ្មី មិនបាននេះទេ ចាស់ក៏វៃដែរមិនដែលរើសទេ ខុបមាថាយប់ឡើងហ៊ានអន្ទុយនិយាយចេះ និយាយពីនេះពីនោះ និយាយពីប្រើអីមិនគិតចេះចុះ តែឮយប់ឡើងបាត់ខ្លួនហើយ ។

ដានី :	ហ៊ុ! គេយកទៅណាទៅ?

សូត្រ :	គេយកទៅវៃដាក់ទំនប់ហ្នឹងឯង ។

ដានី :	មីងដែលឃើញទេ មីងដែលឃើញគេវៃ?

សូត្រ :	ឃើញ យើងឃើញវៃយើងមិនដឹងធ្វើអីគេ ។

ដានី :	ប៉ុនដែលឃើញ?

សូត្រ :	ឃើញ ។

ដានី :	ឃើញៗវៃនៅណា?

សូត្រ :	ឃើញដូចថាទំនប់យើងអញ្ចេះ វៃលើទំនប់ហ្នឹងដូចថាទំនប់នៅត្រឹមនេះ វាអ្នកវៃហ្នឹងឈរចេះ វាឈរខាងនេះមួយខាងនោះមួយទៅត្បូងចប ដាក់កូស អាមួយនោះធ្លាក់ទៅកើតកប់ដីៗទំនប់ហ្នឹង ។

ដានី :	កប់ដីទំនប់ហ្នឹង?

សូត្រ :	ចា៎! វាចេះតែកាយកប់ឲ្យជិតទៅ ព្រឹកឡើងមានមនុស្ស វៃរាល់ថ្ងៃ ។

ដានី :	វៃរាល់ថ្ងៃ?

សូត្រ :	ចា៎! អញ្ចឹងបានខ្ញុំអត់ហ៊ានរត់ហ្នឹង ។

ដានី ៖ អញ្ចឹងពួកអ្នកវៃហ្នឹងពួកអីគេ ពួកអ្នកលើកទំនប់ជុំវិញហ្នឹងអីគ៏?

សូត្រ ៖ ពួកនិរតី ពួកគេហ្នឹងឯង ពួកយើងដែលហ៊ាន ។

ដានី ៖ និយាយទៅពួកអ្នកលើកទំនប់ជាមួយយើង ឬក៏យោធាអី?

សូត្រ ៖ ពួកយោធាគេ គេហៅយោធាមិនអ្នកនោះទេណាស់ ឧបមាថាយោធាគេអ្នកនាំទៅ ប៉ុន វៃមានប្រធានគេធំគេអ្នកម៉ោ អ្នកវៃហ្នឹងផ្សេង ប៉ុន្តែគេករាយការណ៍ទៅមកហើយ ។

ដានី ៖ គេមានកាំភ្លើងដែរ?

សូត្រ ៖ កាំភ្លើងគ្រប់ដៃ ម៉ាកណាក៏មានដែរ អត់តែពួកកងអ្នកស្រុកយើងដែលធ្វើការ ។

ដានី ៖ អញ្ចឹងគេវៃគេអត់យកកាំភ្លើងបាញ់ទេ គេយកត្បូងចបវៃ?

សូត្រ ៖ អត់ទេ!អត់ដែលបាញ់ទេ វៃតែនឹងត្បូងចប ដែកប៉ុននេះដែក អាដែកវែងៗនេះ អាហ្នឹងល្បឿនម៉ាដំបងស្វាត់ៗ មិនបានស្រែករួចទេ បើស្រែកបានតែមុនដំបូងស្រែថា "អ្ហូ!ខ្ញុំមានកំហុសអីបងអើយ!បានយកខ្ញុំម៉ោវៃ កុំបាច់និយាយបាំង មិនដែលបាន និយាយទេ និយាយបានតែ២មាត់ទេ សន្លេកចិត្តណាស់និយាយពីឃើញ ។

ដានី ៖ មីងឃើញច្បាស់ផ្ទាល់ៗភ្នែក?

សូត្រ ៖ ផ្ទាល់ហើយ ។

ដានី ៖ មីងបានឃើញច្រើនដងទេ?

សូត្រ ៖ ខ្ញុំបានឃើញ៣ដង ។

ដានី ៖ ៣ដងហើយឆ្នាំណាខ្លះ?

សូត្រ ៖ គ្មានចាំទេ ខ្ញុំគេវៃដែរ ។

ដានី ៖ មីងគេវៃដែរ វៃកាណាទៀត?

សូត្រ ៖ វៃដេលខ្ញុំប្រាប់ហ្នឹងឯង ។

ដានី ៖ អ្ហូ!វៃកាលគេចាប់ចងមីងគេចអត់ព្រមទៅហ្នឹង?

សូត្រ ៖ ហ្នឹងហើយ ។

ដានី ៖ ដល់ពេលទៅនោះគេអត់វៃទៀតទេ?

សូត្រ ៖ ទេ!ខ្ញុំមិនដែលហ៊ានឈប់ទេ ។

ដានី ៖ ចុះដែលឈឺទេទៅធ្វើការនៅហ្នឹង?

សូត្រ ៖ មិនដែលឈឺទេ ឈឺលមៗខ្ញុំមិនដែលហ៊ានឈប់ទេ ម៉ែឪមិនដឹងថាកូននៅណា ។

ដានី ៖ គាត់អត់ដែលដឹងថាមីងទៅលើកទំនប់នៅហ្នឹងទេ?

សូត្រ ៖ ដឹង ប៉ុន្តែមិនដឹងទៅរកនៅណា ។

ដានី ៖ ចុះមីងគេអត់ដែលឲ្យម៉ោលេងផ្ទះដែរ?

សូត្រ ៖ ទេ!អត់ដែលទេ ។

ដានី ៖ ចុះកន្លែងដេកពេលមីងមានប្រសាសន៍ថាបិទតែធាងត្នោត ធាងអីនៅក្រោមអត់មានកន្ទេល អត់មានភួយ មានខ្នើយអី?

សូត្រ ៖ មានយើងយកទៅ គេឲ្យយកទៅកន្ទេល ។

ដានី ៖ ចុះភួយ ខ្នើយ មុង?

សូត្រ ៖ មុងមានតែមុងប៉ុណ្ណោះទេ ហើយដេកកើយអាសាក់កាដូរយើងប៉ុននេះ ដែលដាក់ផវ៉ាន់ទៅ ។

ដានី ៖ ដេកកើយសាក់កាដូ អញ្ចឹងអត់មានភួយទេ អត់រងាទេកាលហ្នឹង?

សូត្រ ៖ រងារណាស់ ប៉ុនមិនដឹងធ្វើម៉េចបើ អានេះវាយកទៅសម្លាប់តែម្តង ប៉ុនវាមិនថាវាមិនចេះងាប់ ខ្ញុំដើរអត់រួចទេ ដើរទៅម៉ោផ្ទះប្រធានភូមិខ្ញុំនោះ សុទ្ធតែវារ ខ្ញុំវារប្រហែល៣គីឡូ ។

ដានី ៖ វារពីណាម៉ោ?

សូត្រ ៖ វារកន្លែងដែលនៅ កាលលើករួចគេចល័តទៅទៀត ។

ដានី ៖ អ្ហូ!អញ្ចឹងមីងទៅលើកទំនប់ហ្នឹងបានរយៈពេលប៉ុន្មាន?

សូត្រ ៖ រយៈពេលមិនដឹងប៉ុន្មានទេ លើករួចក៏គេដេញទៅទៀតក៏ទៅ ។

ដានី ៖ បានប៉ុន្មានខែដែល?

សូត្រ ៖ នៅបានជាងម៉ា១ឆ្នាំ ជិត២ឆ្នាំនោះ បើគេអ្នកហ៊ានរត់ទៅ គេចេះតែរត់ម៉ោ រត់ម៉ោដេកផ្លូវ២-៣យប់ ដែលយើងដើរអត់រួច ដែលយើងឈឺ អ្នកឈឺរត់ ខ្ញុំអត់ហ៊ានរត់ទេ ខ្ញុំសុខចិត្តងាប់នៅហ្នឹងកន្លែងអត់ហ៊ានរត់ទេ ខ្លះរត់ម៉ោចចកស៊ី តាមផ្លូវដើរមិនដល់ទេ ។

ដានី ៖ រត់ម៉ោពីណាបានចចកស៊ី?

សូត្រ ៖ ដែលគេចល័តទៅទៀត ទៅឆ្ងាយ ។

ដានី ៖ ចល័តទៅណាទៀត?

សូត្រ ៖ ទៅណុះ ។

ដានី ៖ ទៅណា?

សូត្រ ៖ ទៅដល់ស្ពានក្តាម គេចេះតែបញ្ជូនទៅ ខ្ញុំមិនហ៊ានរត់ទេ ខ្ញុំនៅទល់ចប់ៗ គេបញ្ជូនមកស្ទួងទៀតខ្ញុំម៉ោស្ទួងទៀត ។

ដានី ៖ បញ្ជូនម៉ោស្ទួងទៀត?

សូត្រ ៖ ចា៎!ស្ទួងនៅភ្នំលាប ដឹងដល់ភ្នំលាកខ្ញុំដើរអត់រួចទេ ។

ដានី ៖ កាលហ្នឹងមីងឈឺអី?

សូត្រ ៖ ឈឺអត់មានឈឺអីទេ ប៉ុន្តែវាស្គមដាច់ពោះ ឈឺដាច់បាយដែលយើងហូបអត់ឆ្អែត ដល់ឃ្លានមែនទែនហើមៗជើង គេដឹកជញ្ជូនឲ្យម៉ោស្ទួងវិញ ខ្ញុំទៅស្ទួងអត់រួចៗទទួលមារគាត់ទៅឃើញ សួរថាខ្ញុំនៅណា?ខ្ញុំនៅនេះឯងខ្ញុំយំ គាត់ថាលួចឲ្យម៉ោ ។

ដានី ៖ គាត់ដាក់អីម៉ោ?

សូត្រ ៖ ជិះរទេះម៉ោៗជួបយោធាគេ គាត់ថាឈិតងាប់ម្តងទៀត ។

ដានី ៖ ជួបយោធាគេថាម៉េច?

សូត្រ ៖ ជួបទៅគាត់បររទេះរត់ ។

ដានី ៖ អ្នកណាបររត់?

សូត្រ ៖ មារខ្ញុំរស់ដល់សព្វថ្ងៃនេះ បររត់ៗវាតមបាញ់ ដឹងដល់ពេលឆ្ងាយណាស់បានវាឃើញបើនៅជិតអត់បានរស់ទេ ដល់ពេលបររត់ផុតទៅ វាជិះតាម ដល់ពេលទៅគាត់ជាប់ឈ្មោះៗគេវៃសម្លាប់ចោលប្រធានភូមិ ។

ដានី ៖ ភូមិណា?

សូត្រ ៖ ប្រធានភូមិហ្នឹង ។

ដានី ៖ ប្រធានភូមិរាល់ថ្ងៃហ្នឹង?

សូត្រ ៖ ចា៎!ថាគាត់នេះបណ្តោះកូនចៅគេ គេហៅអីយើងទៅនោះគេហៅអីពួកចល័ត គេថាយើងពួករំដោះចល័តគេ ដល់នេះគេហៅទៅៗកន្ទេងវា ទៅកសាងគេថាលើកទី១កសាងគេថាឯងមើលងាយគេ ហើយគាត់ថាគាត់មិនបានយកម៉ោទេ វារត់ម៉ោខ្លួនវាក៏បានសហករណ៍ភូមិយើងទៅៗ ក៏ជួយដោះស្រាយ គេថាលែងធ្វើបាប វារត់ទៅនេះរត់ទៅខ្លួនវាទេ សព្វថ្ងៃឈឺពេញខ្លួន ។

ដានី ៖ កាលលពីមីងចេញពីត្រពាំងថ្មទៅទំនប់ស្ពានស្រែង ទៅទំនប់ត្រស្ពានក្តាមអីហ្នឹងទៅបានប៉ុន្មានឆ្នាំបានលួចម៉ោ បានរយៈពេលប៉ុន្មាន?

សូត្រ ៖ បាននៅភូមិតិចណាស់ បាននៅចំនួនប្រហែលជា ចូលម៉ោភ្លាមបាន៤-៥ខែប៉ុនហ្នឹង ឯង ចាប់យកទៅតែម្តង ។

ដានី ៖ ចុះពេលមីងឃើត្រឡប់ម៉ោផ្ទះហ្នឹងឆ្នាំណា?

សូត្រ ៖ អាយើងម៉ោដល់ផ្ទះហ្នឹងជិតចប់ហើយ ។

ដានី ៖ អញ្ចឹងទៅស្ពានស្រែង ទៅត្រពាំងបក្តាមហ្នឹងអត់បានយូរប៉ុន្មានទេ?

សូត្រ ៖ មិនបានសូវយូរទេ ទំនប់វាអត់សូវធំនោះ លើកដូចថា ដល់ពេលសរុបៗឧបមាថាវាហៅសរុបៗគ្នាទាំងអស់ពីខេត្តនេះ ខេត្តនោះអញ្ចឹងទៅ មនុស្សវាច្រើនទៅអញ្ចឹងវាលឿនៗវាលើករួចទៅវាជញ្ជូនខ្ញុំទៅស្ទឹងទៀត ។

ដានី ៖ បាទ! ពេលទៅស្ទឹងមីងបានម៉ោផ្ទះហ្នុង?

សូត្រ ៖ បានតាគាត់ជួយជញ្ជូនមក ។

ដានី ៖ ពេលម៉ោផ្ទះមីងនៅហ្នឹងរហូត?

សូត្រ ៖ នៅរហូតទល់យួនចូល ។

ដានី ៖ នៅប៉ុន្មានខែបានយួនចូល?

សូត្រ ៖ មិនបានចាំទេ ។

ដានី ៖ ដល់ពេលម៉ោផ្ទះបានហូបចុកអីគ្រប់គ្រាន់ដែរ?

សូត្រ ៖ គ្មានអីទេ បានហូបតែដំឡូង បើដំឡូងបាន បាយដូចថាបេកទៅយើងអត់សូវបានធ្វើ ការម៉ោដល់ឲ្យជួយធ្វើការងារនៅក្នុងភូមិ ឲ្យសម្រាកទៅ វាស្គមទៅមិនរួច ។

ដានី ៖ ប៉ុន្មានខែទៅបានដើររួចអញ្ចឹង?

សូត្រ ៖ ២ខែ ៣ខែនោះបានដើររួច ឃើឡើងបាត់អត់ដឹងខ្លួនអត់ដឹងម៉ែដឹងឪ ដូចថាយើងលាប់ម្តងទៅមកពីបងប្អូនបេះតែស្រណោះឲ្យស៊ីដំឡូង ស៊ីអានេះអានោះទៅលាប់ ។

ដានី ៖ ចុះមីងកាលពីជំនាន់ហ្នឹងមានពួកនិរតី មីងស្គាល់ពួកនិរតីខ្លះទេ?

សូត្រ ៖ បើអ្នកនិរតីក្នុងភូមិនេះស្គាល់ឈ្មោះ ជាតិ ឈ្មោះខុម ឈ្មោះពេញ ។

ដានី ៖ អាហ្នឹងធ្វើអីទេ?

សូត្រ ៖ វាដើរតាមផ្ទះ ដល់យប់ឡើងវាដើរតាមផ្ទះ ។

ដានី ៖ ស្រីឬប្រុសឈ្មោះជាតិ ខុម ពេញហ្នឹង?

សូត្រ ៖ ធំៗហើយ ។

ដានី ៖ ប៉ុន្តែមនុស្សស្រីឬប្រុស?

សូត្រ ៖ មនុស្សស្រី ។

ដានី ៖ ស្រីៗទេ គេដើរមើលនៅតាមភូមិហ្នឹង?

សូត្រ ៖ ភូមិហ្នឹងឯងឧបមាថាគេត្រូវជ្រើសរើសទៅធ្វើទំនប់ ធ្វើការគេធ្វើការដំបូងគេឲ្យប្រធានហ្នឹងហើយអ្នកនាំទៅ ។

ដានី ៖ ចុះមីងដែលឮឈ្មោះយាយថែមទេ?

សូត្រ ៖ ស្គាល់ តែអត់ដែលឃើញរូបទេ ។

ដានី ៖ យាយថែម ធ្លាប់ឮឈ្មោះគាត់ដែរ?

សូត្រ ៖ អ្ហូ!យាយថែមហ្នឹង គ្រាន់តែឃើញស្គាល់ហើយ ។

ដានី ៖ យាយថែមគាត់ធ្វើអី?

សូត្រ ៖ មិនធ្វើអីទេ គាត់ប្រធានធំជាងគេ ។

ដានី ៖ ប្រធានធំ ផ្ទះគាត់នៅណាយាយថែម?

សូត្រ ៖ អត់ដឹងទេ ។

ដានី ៖ អត់ដឹងកាលហ្នឹងឃើញគាត់នៅណា?

សូត្រ ៖ គាត់គ្រាន់តែឃើញកន្លែងធ្វើការហ្នឹង ។

ដានី ៖ ធ្លាប់ឃើញកន្លែងធ្វើការ កន្លែងធ្វើការគាត់នៅណា?

សូត្រ ៖ មិនដឹងនៅណាទេ ប៉ុនឃើញគាត់មកធ្វើការគ្រប់កន្លែងក៏ឃើញតែគាត់ដើរ ជិះឡានក៏ឈប់ទៅក៏ឃើញតែម៉ាភ្លែតក៏ទៅបាត់ ។

ដានី ៖ បាទ!យាយថែមរាងគាត់ម៉េច?

សូត្រ ៖ ធាត់មិនធាត់ ស្គមមិនស្គមល្មម ។

ដានី ៖ ស្គមល្មម?

សូត្រ ៖ រាងខ្មៅ ។

ដានី ៖ អញ្ចឹងគាត់មាឌតូចទេអញ្ចឹង?

សូត្រ ៖ មាឌតូច ។

ដានី ៖ ចុះមីងអត់ដែលឃើញគាត់ផ្ទាល់ទេ?

សូត្រ ៖ ផ្ទាល់តែម៉ាភ្លែតៗ តែមិនដែលហ៊ានមើលមុខទេ ។

ដានី ៖ តែអត់ដឹងយាយថែម គាត់ធ្វើផ្នែកអីទេ?

សូត្រ ៖ អត់ទេ!គាត់ផ្នែកខាងអីៗអត់ដឹងទេ អត់ហ៊ានមើលមុខទេ ។

ដានី ៖ ចុះមីងកាលហ្នឹងយាយថែម គាត់កាចឬស្លូត?

សូត្រ ៖ អត់ដឹងទេ មិនដឹងប្រវត្តិទេ មិនដែលបានទៅឃើញធ្វើការយើងអត់បាននៅជិតជាមួយគាត់ទេ។

ដានី ៖ អត់ដឹងថាគាត់កាចឬស្លូតទេ?

សូត្រ ៖ កាចស្លូតអត់ដឹងទេ ខ្ញុំឃើញតែម៉ាម៉ូយចេះទៅក៏បាត់ទៅ ប៉ុនគេជួបតែប្រធានៗគេ គេសួរនាំពីនេះពីនោះ២-៣មាត់ទៅគេទៅបាត់។

ដានី ៖ ចុះយាយថែម គាត់ម៉ោមានដែលឃើញគាត់ចាប់ពីណា សម្លាប់ពីណាដែរឬអត់?

សូត្រ ៖ អត់ទេ!អត់ដែលឃើញទេ។

ដានី ៖ ប៉ុន្តែគាត់កាចដែរ?

សូត្រ ៖ កាចក៏បើយើងមិនដឹងពីប្រវត្តិគាត់ មិនដែលដឹងចិត្តគាត់យ៉ាំងម៉េច។

ដានី ៖ មិនដែលដឹងចិត្តគាត់យ៉ាំងម៉េចទេ?

សូត្រ ៖ អត់ទេ! គ្រាន់តែឃើញៗថា ដូចប្អូនឯងដើរម៉ោចេះទៅឃើញ ប៉ុន្តែមិនដឹងថាចិត្តប្អូនឯងយ៉ាំងណាទេ។

ដានី ៖ ចុះអត់ដែលជួបប្រជុំអីជាមួយគាត់ទេ?

សូត្រ ៖ អត់ដែលបានប្រជុំទេ បើគេថានោះយាយថែម មកហើយដូចកូនមាន់អញ្ចឹង ក្រាបរាងខ្លួន ឃើញគាត់ បើថាលើកដៃក៏ ដូចថាយើងឈរឲ្យបាត់ហត់បន្តិច ឃើញថាអ្ហូ!នោះយាយថែម មកហើយក៏ សុទ្ធតែរត់។

ដានី ៖ អញ្ចឹងអ្នកធំកាលជំនាន់ហ្នឹងយើងខាចណាស់?

សូត្រ ៖ អ្ហូ!ខ្លាចណាស់។

ដានី ៖ ចុះខ្លាចដូចអ្នកធំយើងឥឡូវឬអត់?

សូត្រ ៖ អ្នកធំយើងឥឡូវខ្លាច តែហ៊ានមើលមុខ ហ៊ាននិយាយរក ហ៊ានសួរថាអ្ហូ!បងទៅណាពូទៅណាអញ្ចឹង បើកាលនោះអត់ហ៊ានសួរទេ ចុះម៉ាមាត់ងាប់ៗ។

ដានី ៖ បាទ!កាលជំនាន់ហ្នឹងដូចជាគណៈឃុំអីយើងហ៊ាននិយាយរកឬអត់ ដូចប្រធានឃុំអី?

សូត្រ ៖ ទល់តែគេសួរយើងបានហ៊ាននិយាយរក។

ដានី ៖ កាលពីជំនាន់ប៉ុល ពត?

សូត្រ ៖ ហ្នឹងហើយសួរថា មិត្តឯងត្រូវទៅខាងណា? ខ្ញុំគេថាឲ្យទៅត្រពាំងថ្ម មិត្តឯងខាងណានេះទៅខាងណា? ខ្ញុំទៅស្ពានស្រែង ហ៊ានប្រាប់។

ដានី ៖ អត់ដែលមានគេសួរសុខទុក្ខអីម៉េចៗអត់ទេ?

សូត្រ ៖ អ្ហ៊ូ!គ្មានទេ ខ្លាចណាស់ ។

ដានី ៖ ខ្លាចគេធ្វើអី?

សូត្រ ៖ ខ្លាចគេវៃចោល ខ្លាចយើងនិយាយទៅខុសដូចថា ហៅគេបងប្ហៅយ៉ាងណា សូប្បីតែហៅ ឪបមាថាចាស់ហៅតាឬហៅអ៊ំក៏ខឹងដែលអត់បានទេ ឲ្យហៅបង តិចហៅតាហៅអ៊ំអីអត់បានទេ ។

ដានី ៖ គេធ្វើម៉េច?

សូត្រ ៖ បើវាហៅទៅវៃចោល វាហៅទៅក៏សាង ប្រាប់យើងឲ្យដឹង ។

ដានី ៖ ប្រាប់ថាម៉េច?

សូត្រ ៖ ប្រាប់ថាថ្ងៃក្រោយកុំហៅចេះ ត្រូវហៅមិត្តបង ដល់សក់ស្កូវហើយយើងត្រូវហៅមិត្តបងយ៉ាងម៉េច ហៅអ៊ំហៅតាអីទៅខឹង អត់ទេមិនឲ្យហៅ ។

ដានី ៖ ចុះបើគណៈឃុំឥឡូវ ប្រធានឃុំឥឡូវ?

សូត្រ ៖ ប្រធានឃុំឥឡូវមានអីឃើញគាត់តាអើយទៅណា? អ៊ើ!អញទៅនោះ ។

ដានី ៖ គាត់អត់អីទេ?

សូត្រ ៖ គ្មានអី ។

ដានី ៖ អត់ខ្លាចដូចមុនទេ?

សូត្រ ៖ អត់ខ្លាចទេ ខ្លាចតែយើងធ្វើខុស យើងមិនខុសយើងទៅខ្លាចអី ឃើញគាត់អ៊ំអើយទៅណា? មីងទៅណា?គាត់ថាអាណាយកមនុស្សទៅវៃចោល ។

ដានី ៖ គាត់ថាអញ្ចឹង?

សូត្រ ៖ គាត់ថា ។

ដានី ៖ ពីអង្កាល់?

សូត្រ ៖ គាត់មួយនោះម៉ោសម្ភាសន៍ខ្ញុំកាលពីថ្ងៃមុននោះ ប្រធានភូមិ ហើយឡើងទៅអង្គុយហ្នឹងទៀតប្រធានអីឡើងញ៉ែរអស់ ។

ដានី ៖ អញ្ចឹងប្រធានភូមិអីអត់ខ្លាចដូចមុនទេ?

សូត្រ ៖ ទេ!អត់ខ្លាចដូចមុនទេ ។

ដានី ៖ ចុះមីងកាលហ្នឹងពេលដែលឈឺម៉ោនៅផ្ទះហ្នឹង ខាងប្រធានភូមិប្រធានអីគេអត់ថាអី ទេ?

សូត្រ ៖ អ៊ើ!អត់ថាអីទេ ។

ដានី ៖ កាលយើងដើរអត់រួច ម៉ោពី?

សូត្រ ៖ ប្រធានភូមិគេយំហ្នឹ ។

ដានី ៖ បាទ!ប៉ុន្តែកាលហ្នឹងជំនាន់ប៉ុល ពតយើងរៀបម៉ោកាលហ្នឹងគេមិនចាប់គាត់ទៅកសាង ទៅអី អញ្ចឹងមីងនៅក្នុងភូមិនេះគេអត់រករឿងទេ?

សូត្រ ៖ អត់ទេ!ឲ្យតែបានម៉ោដល់ដឹងតែជួយ បើអញ្ចឹងងាប់អស់ ។

ដានី ៖ ពីណាជួយ?

សូត្រ ៖ ដូចថាប្រធានភូមិ ប្រធានក្រុមស្រុកយើងហ្នឹង ។

ដានី ៖ ចុះក្រែងពួកនិរតីគេនៅកាន់កាប់?

សូត្រ ៖ កាន់កាប់ក៏មិនសូវអីទេ ឲ្យតែនៅភូមិយើង ស្គាល់គាត់ខ្លះ ឲ្យតែម៉ោចេះជួយដែលអត់អីទេ ។

ដានី ៖ ខ្លាចតែទៅតាមកងចល័ត កងអីអត់បានទេ?

សូត្រ ៖ អត់បានទេ តែម៉ោជួយលាក់ជួយអីដូចថា យើងទៅសួរថា យើងទៅសុទ្ធតែខ្ញុំឈ្មោះសូត្រអញ្ចឹង ខ្ញុំដាក់ឈ្មោះផ្សេង ។ កាលរត់ទៅភូមិ វាដើរម៉ោវាមកសួររកក្នុងភូមិយើងអត់ស្គាល់ យើងដាក់ឈ្មោះផ្សេង បើថាយើងដាក់ឈ្មោះដដែលតែវាម៉ោសួរស្គាល់អូសវិញដឹងតែងាប់ហើយ ដឹងតែខ្ទប់ទំនប់ហើយ ។

ដានី ៖ បាទ!ចុះមីងនៅពេលបែក ពេលយួនចូលម៉ោនៅស្រុកហ្នឹងរហូត?

សូត្រ ៖ នៅរហូត ។

ដានី ៖ អញ្ចឹងមីងរៀបការឆ្នាំណា?

សូត្រ ៖ ខ្ញុំមិនដឹងប៉ុន្មានទេ ខ្ញុំមិនមែនរៀបការទេ ខ្ញុំបាននេះអាក្រក់ហ្នឹងមិនបានការទេ សម័យយួន ខ្ញុំបានគ្នាសម័យយួន ។

ដានី ៖ ថាម៉េចខ្ញុំស្តាប់អត់ទាន់ អ្ហូ!មីងអត់បានរៀបការទេយ៉ាងម៉េច?

សូត្រ ៖ សម្រេចតាមចិត្តឯង ។

ដានី ៖ ការគ្រាន់តែយើងជួបគ្នា?

សូត្រ ៖ ដូចថាចាស់ៗទៅក៏សែនទៅ កាលនោះគ្មានអី រកតែឆ្នាំងដាំបាយបានមាន ។

ដានី ៖ បាទ!ចុះមីងអត់ដែលទៅទំនប់ត្រពាំងថ្មទេឥឡូវ?

សូត្រ ៖ ទេ!មិនដែលបានទៅទេ ។

ដានី ៖ អត់ដែលបានទៅមើលត្រពាំងថ្មកន្លែងមីងទៅលើកពីមុនទេ?

សូត្រ ៖ ទៅបាត់តាំងពីមករំលំរឹករហូតមកសព្វថ្ងៃ អត់ដែលឃើញទេ ។

ដានី ៖ អត់ដែលឃើញទេ?

សូត្រ ៖ ទេ!មិនដែលឃើញទេ វាដូចបាក់ស្បាត មិនចង់ទៅទៀតទេ ឃើញកន្លែងឃើញអីក៏វាវេទនា ។

ដានី ៖ ចុះមានដែលព្ទ ឥឡូវគេបង្កើតតុលាការអីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម មីងដែលព្ទទេ?

សូត្រ ៖ មិនដែលបានបើក ។

ដានី ៖ ប៉ុន្តែព្ទគេកាត់ទោសអីប្អអត់?

ជិតខាង ៖ ឃើញ ។

ដានី ៖ ឃើញប៉ុន្តែមីងអត់ដែលឃើញទេ?

ជិតខាង ៖ គាត់មិនដែលបានបើកទេ ។

សូត្រ ៖ ខ្ញុំមិនដែលបានបើកទេ ខ្ញុំនៅតែវាល មិនដែលបានបើកទេ ។

ដានី ៖ អត់ដែលដឹងទេ?

សូត្រ ៖ ទេ ។

ដានី ៖ អញ្ចឹងរាល់ថ្ងៃហ្នឹងអ្នកដែលធំៗកាលពីសម័យប៉ុល ពតហ្នឹងដូចថាអ្នកដឹកនាំប្រទេសកាលពីហ្នឹង ឥឡូវហ្នឹងគេចាប់គាត់ គេកំពុងតែកាត់ទោសគាត់រាល់ថ្ងៃហ្នឹង បាទ!ដូចជាប្រធានគុកទួលស្លែង កាំង ហ្គេចអ៊ាវហៅឌុចហ្នឹងគេកាត់ទោសគាត់ហើយៗ ឥឡូវហ្នឹងថ្ងៃទី២៧ខែហ្នឹងគេចាប់ផ្តើមបើកសវនការបឋម បើកដំបូងកាត់ទោសមេដឹកនាំជាន់ខ្ពស់៤រូប មាននួន ជា អៀង សារី ខៀវ សំផនហើយនឹងប្រពន្ធរបស់អៀង សារី ៤នាក់គេចាប់ផ្តើមកាត់ទោសគាត់ ។

សូត្រ ៖ ខ្ញុំដែលនៅកន្លែងធ្វើការស្គាល់តែខៀវ សំផន មិនស្គាល់ទេប៉ុន្តែព្ទ ។

ដានី ៖ ព្ទគាត់ថាម៉េច?

សូត្រ ៖ ទេ!កាលហ្នឹងព្ទមិនថាអីផង ។

ដានី ៖ ចុះមីងបើតាមចិត្តមីង មីងចង់ឲ្យគេកាត់ទោសដែលប្អអត់?

សូត្រ ៖ កាត់ទៅ ។

ដានី ៖ ម៉េចបានថាកាត់ៗទៅ?

សូត្រ ៖ កាលនោះធ្វើបាបខ្ញុំទាំងអស់គ្នា ។

ដានី ៖ ធ្វើបាប មីងចង់ឲ្យគេកាត់បន្ថែមទៀតឬអត់ ចង់កាត់មនុស្សថែមទៀតឬក៏?

សូត្រ ៖ ចង់ ។

ដានី ៖ ចង់កាត់ថែមទៀត?

សូត្រ ៖ ព្រោះធ្វើបាបមនុស្សផាប់អស់ ។

ដានី ៖ អញ្ចឹងមីងខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំមីងទៀតហើយ អញ្ចឹងមីងមានអីចង់បន្ថែមនូវអាអ៊ីដែលខ្ញុំមិនបានសួរនាំមីង?

សូត្រ ៖ បានហើយអរគុណ! ចាំបានប៉ុននេះឡើងចង់វង្វេងអស់ រកនឹក វាមិនរកនឹកអីទេ វាភ័យ ។

ដានី ៖ អ្ហ៊ូ!ភ័យ?

សូត្រ ៖ ភ័យថាសព្វថ្ងៃខ្ញុំរោគច្រើនណាស់ រោគខ្សោយ រោគច្រើនណាស់ ។

ដានី ៖ អ្ហ៊ូ!តែឥឡូវមីងបាត់ភ័យឬនៅ?

សូត្រ ៖ អន់ហើយ បាត់ហើយ ។

ដានី ៖ បាទ!អញ្ចឹងខ្ញុំអរគុណមីងច្រើន ។

សូត្រ ៖ ចា៎!

«ចប់»